ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# ឯកសារជំនួយស្មារតី

ក្រោយប្រតិបត្តិការ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅមានបញ្ហាសេសសល់មួយចំនួន ដែលចាំបាច់ត្រូវដោះស្រាយ នោះគឺៈ

- ទប់ស្កាត់បញ្ហាថ្មីដែលកើតឡើងក្នុងអំឡុងពេលមិនទាន់មានច្បាប់អនុញ្ញាតឲ្យខ្ចីពរពោះជំនួស
- ជួយឲ្យស្ត្រីដែលបានពរពោះហើយ រួចផុតពីភាពរងគ្រោះ ដោយខ្វះការថែទាំរហូតដល់ទារកកើត
- ជួយទារកឲ្យមានអាណាព្យាបាលចិញ្ចឹម បីបាច់ ថែទាំពិតប្រាកដ ។

បន្ទាប់ពីបានធ្វើប្រតិបត្តិការ បង្ក្រាបដើម្បីទប់ស្កាត់ករណីពរពោះ ដែលធ្វើឡើងដោយជនជាតិអូស្ត្រាលី សហការជាមួយជនជាតិខ្មែរ ពីររូប ដើម្បីប្រមូលស្ត្រីខ្មែរ ឲ្យពរពោះបាន ២៣នាក់ និងបាន សម្រាលកូនហើយ៥នាក់ និងមានទារក ៦ រូបមក មានចំណោទមួយបានចោទឡើងថា តើត្រូវដោះស្រាយដូចម្តេចបន្តទៀត ?

ពាក់ព័ន្ធនឹងការពរពោះជំនួសនេះ មានដំណាក់កាលបីត្រូវដោះស្រាយ គឺៈ

១. *ដំណាក់កាលមុនពេលពរពោះ* ៖ ត្រូវមានបែបបទនីតិវិធីមួយ ដែលធានាសុវត្ថិភាពចំពោះជីវិតម្តាយ និងទារក តាំងពីពេលសាកល្បង រហូតដល់កូនកើត រួមទាំងលក្ខ័ណ្ឌមួយចំនួនពាក់ព័ន្ធ នឹងអ្នកស្នើសុំ(ស្ថានភាពគ្រួសារ ស្ថានភាពទ្រព្យសម្បត្តិ លិខិតថ្កោលទោស គោលបំណងនៃការចង់បានកូន កិច្ចសន្យាពាក់ព័ន្ធ នឹងការទទួល ឬចិញ្ចឹមបីបាច់កូន ...) អ្នកពរពោះ (ឧ. អ្នកធ្លាប់ផ្តល់កំណើត សុខភាព ការឯកភាពពីសហព័ទ្ធ ការដឹងឮពីអាជ្ញាធរ, ...) ។ កន្លងមក មានករណីដែលកូនកើតមកមិនគ្រប់លក្ខណៈ មិនទទួលយក ឬបញ្ចុះតម្លៃ ដែលជាការ តថ្លៃជីវិតទារក តាំងពីនៅក្នុងពោះ ហើយកូនទាំងនេះ នឹត្រូវបានគេបោះបង់ ក្នុងដំណាក់កាលណាមួយ ។

២. *តំណាក់កាលក្នុងពេលពរពោះរហូតទារកកើត*៖ ត្រូវមានដូចជា លិខិតបញ្ជាក់អាជីព និងឯកទេសរបស់របស់គ្រូពេទ្យ លិខិតទទួលស្គាល់របស់ក្រសួងសុខាភិបាលលើការធានារបស់គ្រឹះស្ថាន ឬមន្ទីរពេទ្យទៅលើឯកទេស ឬសម្ភារៈ ឧបករណ៍ដែលមានសម្រាប់ត្រូវការ ត្រូវមានការថែទាំ និងផ្គត់ផ្គង់សមស្រប ដែលអាចធានា ការពរពោះ ទាំងម្ដាយ និងទារកបានល្អ....និងការតាមដានការវិវត្តន៍នៃដំណើរការ

៣. *តំណាក់កាល នាំទារកចេញទៅប្រទេសគោលដៅ*៖ កូនដែលកើតឡើងដោយការពរពោះជំនួស គឺមានគោលដៅយកចេញទៅនៅជាមួយអ្នកដែលធានាថាជាអាណាព្យាបាល ឬជាឪពុក ។ ប៉ុន្តែ ការបារម្ភគឺ កូនទាំងនោះ នឹងមានសំណាងអាក្រក់ បើសិនជាការនាំចេញ មិនមានការធានាត្រឹមត្រូវ ព្រោះកន្លងមក នីតិវិធីនៃការនាំចេញ ហាក់ដូចជាធ្វើឡើងតាមរយៈអន្តរាគមន៍ ច្រើនជាងបែបបទផ្លូវច្បាប់ និងពុំមានបញ្ជាក់អំពីអត្តសញ្ញាណ និងការធានារបស់អ្នកដែលនាំកូនចេញទៅឡើយ ។

ដើម្បីដោះស្រាយបញ្ហានេះ ក្នុងតួនាទីជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានកោះប្រជុំជាបន្ទាន់ ចំនួន ០៤លើក និងមានជំនួបដោយឡែកជាមួយតំណាងស្ថានទូតអូស្ត្រាលី ០២លើក៖

**កិច្ចប្រជុំលើកទី១**៖ នៅថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ការិយាល័យប្រឆាំងការជួញដូរមនុស្សរាជធានីព្រះអាជ្ញារងរាជធានី តំណាងក្រសួងសុខាភិបាល តំណាងក្រសួង អង្គការពាក់ព័ន្ធដទៃទៀត រួមទាំងតំណាងស្ថានទូតអូស្ត្រាលី ប្រាំមួយរូប ដើម្បីពិភាក្សាគ្នារកដំណោះស្រាយ ។

**លទ្ធផល**៖ ក្នុងការពិភាក្សា ភាគីអូស្ត្រាលីព្យាយាមគេចពីការទទួលខុសត្រូវ ហើយបកស្រាយតាមច្បាប់អូស្ត្រាលី ដែលចាត់ទុកថា ការពរពោះជំនួស ជាសិទ្ធិឯកជន មិនពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋាភិបាលអូស្ត្រាលីទេ ។

ដើម្បីបន្តការដោះស្រាយ នាងខ្ញុំបានស្នើឡើងនូវវិធានការ បីចំណុច ៖

ទី១. សុំឲ្យភាគីអូស្ត្រាលីផ្អាកទទួលការស្នើសុំការពរពោះជំនួសនេះ មកអនុវត្តនៅកម្ពុជាសិនដើម្បីកុំឲ្យមានការបង្កើតករណីថ្មីទៀត ក្នុងអំឡុងពេលដោះស្រាយករណីដែលមានរួចហើយ

ទី២. ដោះស្រាយករណី កូនដែលកំពុងនៅក្នុងផ្ទៃរបស់ស្ត្រី ១៨នាក់ទៀត និងកូនដែលមិនទាន់បានយកចេញទៅអូស្ត្រាលីនៅឡើយ គឺតម្រូវឲ្យយកថវិកាដែលជនសង្ស័យទទួលបានពីអ្នកចង់បានកូន មកបន្តឧបត្ថម្ភស្ត្រីពរពោះ តាមការសន្យា រហូតដល់កូនកើតដោយសុវត្ថិភាព និសុំសហា

ការឲ្យភាគីអូស្ត្រាលី រកអ្នកចេញមុខទទួលខុសត្រូវក្នុងការធ្វើជាឪពុក ឬម្តាយដោយស្របច្បាប់ចំពោះទារកទាំងនោះ

ទី៣. និងសុំឲ្យភាគីអូស្ត្រាសហការរៀបចំបែបបទនីតិវិធីរួមគ្នា ឲ្យបានសមស្រប ដើម្បីដោះស្រាយការយកទារកចេញទៅប្រទេសខ្លួនដោយស្របច្បាប់ និងផ្អាកការផ្តល់សេវារហូតដល់មានច្បាប់អនុញ្ញាតជាថ្មី ។

សំណូមពរទាំងបីនេះ ត្រូវបានទទួលការឯកភាព ពី**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគ.ជ.ប.ជ** តាមចំណារលើរបាយការណ៍របស់ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

**<u>ជំនួបជាមួយតំណាងស្ថានទូត អូស្ត្រាលី</u>**៖ នៅថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១៦ លោកស្រី Lauren Tuohy លេខាទី១ស្ថានទូតអូស្ត្រាលី និងលោកស្រី ប្រធានកុងស៊ុល បានសុំជួបពិភាក្សាជាមួយខ្ញុំ (ជូ ប៊ុនអេង)នៅសណ្ឋាគារ Cambodiana ដើម្បីសុំដំណោះស្រាយលើករណីអ្នកដែលចង់បានទារកយកទៅអូស្ត្រាលី ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំបានជម្រាបពីដំណោះស្រាយដោយ នៅតែទទូចឲ្យមានកិច្ចសហការពីភាគីអូស្ត្រាលី ដើម្បីសម្រាលទម្ងន់ទោសអ្នកស្រីTammy និងអាចអនុញ្ញាតឲ្យគាត់បន្តការសន្យាជាមួយស្ត្រីពរពោះ រហូតចប់ចុងចប់ដើម និង បញ្ចប់ ។ ដំណោះស្រាយបន្ត គឺទាមទារឲ្យមានកិច្ចសហការពីជនជាប់ចោទ (លោកស្រី Tammy) និងបក្ខពួកខ្លួន បង្ហាញបញ្ជីស្ត្រីដែលបានទទួលសេវា និងដាក់តម្កល់ថវិកាសម្រាប់ការថែទាំបន្ត ដល់ស្ត្រី ដែលបានពរពោះរួចហើយតាមការសន្យា ហើយផ្អាកការបង្កើតករណីថ្មី ។ តុលាការ ក៏បង្គាប់ឲ្យ Tammy យកបញ្ជីឈ្មោះអ្នកស្នើសុំ មកបង្ហាញផងដែរ តែស្ត្រីរូបនេះ មិនទាន់បង្ហាញពីកិច្ចសហការគ្រប់គ្រាន់នៅឡើយ នៅរកលេសគេចវេសជាបន្តបន្ទាប់ ដែលចាំបាច់ត្រូវបន្តការចោទប្រកាន់បន្តទៀត ។

**<u>កិច្ចប្រជុំលើកទី២</u>**៖ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋាន បានជួបប្រជុំចង្អៀតមួយ ដែលមាននាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស ការិយាល័យ ប្រឆាំងការជួញដូរមនុស្សរាជធានី ព្រះរាជអាជ្ញា និងចៅក្រមសាលាដំបូងរាជធានី អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មចូលរួម ដើម្បីពិនិត្យតាមដានដំណើរការនៃការផ្តល់សេវាជូនស្ត្រីពរពោះ ។

**<u>លទ្ធផល</u>**៖ ព្រះរាជអាជ្ញា និងចៅក្រម សាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា ជនជាតិអូស្ត្រាលីភេទស្រី ឈ្មោះ Tammy និងជនជាតិខ្មែរ ពីនាក់ទៀត ត្រូវបានចោទប្រកាន់ពីការធ្វើអន្តរការីក្នុងការជួលស្ត្រីខ្មែរឲ្យពរពោះជំនួស ក្នុងអំឡុងពេលដែលមានការហាមឃាត់ពីក្រសួងសុខាភិបាល

ខុសនឹងច្បាប់រដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ និងការប្រើឯកសារក្លែងបន្លំដើម្បីនាំទារកចេញពីកម្ពុជា ។

លោកជំទាវ ជូ ប៊ុនអេង បានណែនាំឲ្យជម្រុញឲ្យ Tammy សហការផ្តល់បញ្ជីឈ្មោះ និងសាវតាពាក់ព័ន្ធរបស់ស្ត្រីដែលពរពោះ និងបញ្ជីអ្នកស្នើសុំ ដើម្បី ៖

១. បានបន្តផ្តល់សេវាដល់ស្ត្រី និងបានអប់រំណែនាំមិនឲ្យធ្វើសកម្មភាពនេះបន្តទៀត

២. បានសម្រាលការចោទប្រកាន់ពីការនាំទាកចេញដោយមិនមានការទទួលខុសត្រូវ ទៅជារកអ្នកទទួលខុសត្រូវ ឲ្យបានជាក់លាក់ និងហ៊ានធានាចំពោះមុខច្បាប់ ។

៣. បានសិក្សាតាមដានបន្តចំពោះដំណើរការរបស់ក្រុមហ៊ុនដែលធ្វើអាជីវកម្មនេះ ដើម្បីឈានដល់ការរៀបចំនីតិវិធីច្បាប់ឲ្យបានត្រឹមត្រូវ ។

៤. អាចបន្ធូរបរិយាកាស ដើម្បីឲ្យអ្នកពាក់ព័ន្ធចេញមុខមកទំនាក់ទំនង និងអាចបន្តស្រាវជ្រាវរកក្រុមដទៃទៀតដែលកំពុងតែមានដំណើរការយ៉ាងស្ងៀមស្ងាត់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**<u>កិច្ចប្រជុំលើកទី៣</u>៖** ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានកោះប្រជុំមន្ត្រីបច្ចេកទេសពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាកម្ម ការិយាល័យប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញ ដើម្បីពិនិត្យលទ្ធភាពក្នុងការរៀបចំបទដ្ឋាន និងនីតិវិធីសមស្របសម្រាប់ការនាំយកទារកចេញដោយស្របច្បាប់ ។

**<u>លទ្ធផល</u>៖** អង្គប្រជុំបានស្នើសុំឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងក្រសួងការបរទេស សិក្សាលើឯកសារ ដែលធ្លាប់បានអនុវត្តកន្លងមក ថាតើនៅខ្វះខាតត្រង់ណា ដែលត្រូវបំពេញបន្ថែម ឲ្យទៅជាឯកសារស្របច្បាប់ដែលមានការធានាសុវត្ថិភាពកុមារ ពីការរត់ពន្ធ ការជួញដូរ និងការកេងប្រវ័ញ្ចនានា ហើយត្រៀមកិច្ចប្រជុំលើកទី៤ ។

**<u>សំណើសុំអន្តរាគមន៍ពីស្ថានទូតអូស្ត្រាលី</u>៖**

ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៦ ប្រតិភូស្ថានទូតអូស្ត្រាលីបានចូលជួបសុំអន្តរាគមន៍ពី**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដើម្បីឲ្យបុរសជនជាតិអូស្ត្រាលី មួយរូបនាំយក<u>ទារកភ្លោះមួយគូ</u> ចេញពីកម្ពុជា ។ ទោះបីយ៉ាងនេះក្តី **សម្តេច**បានបញ្ជាក់ពីជំហរថាត្រូវរៀបចំបែបបទនីតិវិធីឲ្យបានសមស្រប និងធានាភាពស្របច្បាប់សម្រាប់សុវត្ថិភាពកុមារ ។

**<u>កិច្ចប្រជុំលើកទី៤</u>៖** ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានជួបប្រជុំសារជាថ្មី នៃក្រុមការងារពាក់ព័ន្ធនឹងការរៀបចំឯកសារ បែបបទ និងនីតិវិធី នៃការនាំទារកចេញពីកម្ពុជា។

**<u>លទ្ធផល</u>៖** មន្ត្រីជំនាញពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រុមប្រឹក្សានីតិកម្ម ក្រសួងការបរទេស និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានលើកយកសំណុំឯកសារដែលធ្លាប់បានប្រើប្រាស់កន្លងមកក្នុងការនាំទារកចេញពីកម្ពុជា ដើម្បីសិក្សាពីចំណុចខ្វះចន្លោះ មានន័យថា ឯកសារសម្រាប់ការនាំទារកចេញ មិនគ្រប់គ្រាន់សម្រាប់ធានាដល់សុវត្ថិភាពទារក ឬកុមារឡើយ ។ ហេតុនេះ ជាការសម្រេចចិត្ត ត្រូវកំណត់យកដំណោះស្រាយដំណាក់កាលនាំយកទារកចេញ ដែលជាដំណាក់កាលចុងក្រោយដើម្បីបញ្ចប់បញ្ហា ។ អង្គប្រជុំបានឯកភាព កំណត់បែបបទ និងនីតិវិធីសមស្របមួយ ដែលធានាដល់សុវត្ថិភាពកុមារ រួមទាំងមានការតាមដានបន្ត លើការអភិវឌ្ឍន៍រីកចម្រើនរបស់ទារក ។ (មានរបាយការណ៍ជូនភ្ជាប់មកជាមួយ ) ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម**សម្តេចក្រឡាហោម** មេត្តាជ្រាបជារបាយការណ៍ជំនួយស្មារតី ដ៏ខ្ពង់ខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**